# ទំនុកប្រាជ្ញា

មានទំនុកដំកើងជាច្រើនជាសេចក្ដីអធិស្ឋានទៅកាន់ព្រះ ហើយយើងបានឃើញមានឧទាហរណ៍នេះនៅក្នុងទំនុកតម្អូញ និងទំនុកអរព្រះគុណ។ ប៉ុន្តែ ទំនុកដំកើងភាគច្រើននៃទំនុកតម្អូញ និងទំនុកអរព្រះគុណ គឺជាការឆ្លុះបញ្ចាំងជាជាងសេចក្ដីអធិស្ឋាន។ ជួនកាល គេបានហៅទំនុកដំកើងទាំងនេះជា ការទូន្មាន(ដំបូន្មាន) ពីព្រោះទំនុកដំកើងទាំងនេះបង្រៀនគំនិតសំខាន់ៗជាច្រើនផ្សេងៗគ្នា។ សូម្បីតែ ទំនុកដំកើងទាំងនោះមិនភ្ជាប់ទៅនឹងការក្រើនរំលឹកដាស់តឿនក្ដី អ្នកទំនុកដំកើងអាចបង្រៀនដោយគ្រាន់តែផ្ដល់ដល់អ្នកអាន នូវសារៈសំខាន់នៃការឆ្លុះបញ្ចាំងនឹងទំនុកដំកើងទាំងនោះលើប្រធានបទជាក់លាក់ផ្សេងៗ ។ មានបីក្រុមនៃទំនុកដំកើង ដែលអាចបែងចែកនៅក្នុងប្រភេទទំនុកដំបូន្មាន មាន (១) ទំនុកប្រាជ្ញា (២) ទំនុកតូរ៉ា និង (៣) ទំនុកប្រវត្តិសាស្ត្រ (៧៨, ១០៥, និង១០៦)។ យើងនឹងពីភាក្សាចំណុចទាំងពីរ ប៉ុន្តែយើងមិនពីភាស្សាចំណុចទីបីទេ ព្រោះយើងបានបញ្ចូលជំពូកទាំងនោះ នៅក្នុងប្រវត្តិសាស្ត្រក្នុងទំនុកដំកើងរួចមកហើយ។

ទំនុកប្រាជ្ញាបង្ហាញនូវឥទ្ធិពលនៃផ្លូវជាក់លាក់នៃគំនិតជីវិត និងជំនឿ។ ផ្លូវនៃការគិត និងការធ្វើទេវសាស្ត្រត្រូវបានបង្ហាញយ៉ាងល្អបំផុតនៅក្នុងកណ្ឌយ៉ូប សុភាសិត និងសាស្ដា។ ...

និយមន័យ និងការពណ៌នាទំនុកប្រាជ្ញា

ការសំគាល់ទំនុកប្រាជ្ញា

១. សំគាល់ទម្រង់អក្សរសាស្ត្រជាសុភាសិត៖ 37:1-2

កុំឲ្យក្ដៅចិត្ត ដោយព្រោះមនុស្ស
ដែលប្រព្រឹត្តអាក្រក់ឡើយ
ក៏កុំឲ្យច្រណែននឹងពួកអ្នកដែលធ្វើការទុច្ចរិតដែរ

២ ដ្បិតនៅបន្តិចទៀត គេនឹងត្រូវច្រូតកាត់ដូចជាស្មៅ
ហើយនឹងក្រៀមស្វិតទៅ ដូចជាស្មៅខ្ចីដែរ។

២. ជាសេចក្ដីបង្រៀន ឬការអាក្រក់

37:9

ពីព្រោះពួកអ្នកដែលធ្វើអាក្រក់ នឹងត្រូវកាត់ចេញ
តែអស់អ្នកដែលរង់ចាំព្រះយេហូវ៉ា
នោះនឹងបានផែនដីជាមរដក

៣. ការប្រើពាក្យប្រដូច «ដូចជា»

128:3

ប្រពន្ធឯងនឹងបានដូចជាដើមទំពាំងបាយជូរមានផ្លែ

ដែលដាំនៅក្នុងទីធ្លានៃផ្ទះឯង
កូនឯងទាំងប៉ុន្មាន នឹងបានដូចជាដើមអូលីវនៅជុំវិញតុ
របស់ឯង

## ៤. ការប្រើពាក្យ «មានពរហើយ»

1:1; 34:8b; 112:1b; 127:5

## ៥. ការប្រើពាក្យ «កូនអើយ»

34:11